ខាង ហើយវិលត្រឡប់មកដល់នគរដើមរបស់ខ្លួនវិញ គេក៏សម្លាប់បូជាយិជនៅពេលនោះទៅ ចាត់ជាពិធីដ៏ស័ក្តិសិទ្ធិតាមលទ្ធិសៃយ-វេទ» ។

គ្រានោះជារាត្រីកាលនៃថ្ងៃពេញបូណ៌មី ខែចេត្រ ព្រះមហារាជយុធិស្ឋិរបានឲ្យគេលែងសេះសនេះ ឲ្យត្រាច់រង្គាត់ទៅជាគ្រឿងសម្ដែងព្រះរាជបំណងរបស់ព្រះអង្គនឹងធ្វើពិធីអស្វមេធ ។ អរជុនអ្នកដឹកដោយតាមក្រោយពាជីទៅក្នុងគ្រានោះ បានទៅជួបប្រទះប៉ះទង្គិចនឹងភ័យជាច្រើនលើក ។ គ្រាដំបូងបានទៅជួបប្រទះប្រយុទ្ធនឹងព្រះរាជាក្រុងមាលវៈ ដែលទ្រង់បានចាប់ឃុំខាំងសេះនោះទុក ប៉ុន្តែអរជុនច្បាំងឈ្នះ ទើបព្រះរាជាអង្គនោះ លើកវេហ៍ពលតាមអរជុនទៅជាសម្ព័ន្ធមិត្រ ។ កាលសេះចេះតែត្រាច់រង្គាត់ទៅមុខទៀត ក៏មានការជួបប្រទះតស៊ូគ្នាដោយអន្លើ ៗ ។ គ្រាមួយនោះ ពាជីដើរចូលទៅជាន់រាជអាណាចក្រមណីបុរ ។ ព្រះរាជាប្រទេសនោះ មិនព្រមទទួលស្គាល់ថាជាក្សត្រិយ៍ធំចម្បង ។ អរជុនបានផ្ចាលផ្ចាញ់ព្រះរាជាអង្គនោះ ឲ្យខ្លបខ្លាចត្រឡប់ជាមានព្រះទ័យស្រឡាញ់រាប់អានជាសម្ព័ន្ធមិត្រ ។ សេះសត្រាច់ចរចេញពីព្រះនគរនោះទៅទៀត របូតដល់វិលត្រឡប់មកចូលក្នុងព្រះនគរដើមវិញអស់វេលាមួយឆ្នាំគត់ ។ ក្នុងរវាងពេលមួយឆ្នាំនោះ ព្រះមហារាជយុធិស្ឋិរ ទ្រង់ខំបំពេញតបៈយ៉ាងតឹងរឹងខ្ជាប់ខ្ជួនដូចជាតាបសឬសីក្នុងព្រៃភ្នំ គឺក្នុងមួយថ្ងៃ ៗ ទ្រង់សោយ



តែមួយពេល ។ វៀរចាករបស់ស្រស់ និងចម្អាប ហើយទ្រង់ផ្ទំតែលើផែនដី ។ កាលដល់ចុងឆ្នាំ អរជុនបានវិលត្រឡប់មកដល់ក្នុងព្រះនគរវិញ ព្រមទាំងពាជី មានការទទួលជាឱឡារិក រីករាយសប្បាយទូទាំងក្រុង ដ្បិតកងទ័ពមានជោគជ័យ ហើយត្រឡប់ចូលក្នុងក្រុងវិញ បានទទួលបដិសណ្ឋារៈ និងបំណាច់រង្វាន់យ៉ាងពេញចិត្តទាំងនាំគ្នាស្រែកហ៊ោតឹកកងរំពងពេញក្រុង ។

នៅថ្ងៃពេញបូណ៌មី ខែមាឃជាថ្ងៃដែលកំណត់ធ្វើពិធីអស្វមេធនៅទីដីស័ក្តិសិទ្ធិមួយកន្លែងដែលគេបានត្រៀមទុកមកអំពីមុនសំរាប់ធ្វើការនេះ ។ គេបានអញ្ជើញក្សត្រិយ៍នៅប្រទេសជិតខាងមកប្រជុំក្នុងពិធីសម័យនេះដែរ ។ សង់ព្រះពន្លាបិទមាសប្រាលវន្ទាលជាឱឡារិកសម្រាប់ទទួលក្សត្រិយ៍បរទេសទាំងឡាយដែលមកកាន់ព្រះរាជសំណាក់ មានបារាំទាប ៗ សម្រាប់ទទួលអ្នកមានបណ្ដាស័ក្តិតូច ៗ តាមលំដាប់ចុះមក ឯពួកជីព្រាហ្មណ៍ឲ្យនៅបារាំមួយដោយឡែកផ្សេង ។ សង់សុវណ្ណមណ្ឌបមួយខ្នងក្នុងព្រះមហារាជវាំង រៀបចំទីអង្គុយទុកជុំវិញមណ្ឌបនោះ, ពួកជីព្រាហ្មណ៍អ្នកធំ ៗ អង្គុយក្បែររាជបល្ល័ង្ក, អ្នកតូច ៗ ជាឋានានុក្រមចុះមកអង្គុយឃ្លាតចេញទៅជាសង្កាត់ ៗ រៀងរាយវែងឆ្ងាយទៅ ។ នៅលើវេទិកាដ៏ខ្ពស់ក្រាលដោយសុវណ្ណភូសា តាំងបល្ល័ង្កពីរដ៏ធំខ្ពស់, បល្ល័ង្ក ១ សម្រាប់ព្រះមហារាជធូតរាស្ត្រ បល្ល័ង្ក ១ ទៀតសម្រាប់ព្រះមហារាជយុធិស្ឋិរ ។ ខត្តិយានារី

ទាំងឡាយអង្គុយរៀងរាយតាមទីកន្លែង ដែលគេបានកំណត់ទុកជាស្រេចនៅខាងរាជបល្ល័ង្ក ។

កាលបើពួកភ្ញៀវអញ្ជើញមកចូលអង្គុយតាមអណ្តាប់អណ្តោយ តាមទីកន្លែងរៀបរយស៊ប់សួនហើយ គេចាប់ផ្តើមធ្វើពិធីនោះ ។ ព្រះមហារាជយុធិស្ឋិរ និងព្រះនាងទ្រៅបទី ចងចុងជាយព្រះភូសាភ្ជាប់គ្នាតាមបែបដែលធ្លាប់ប្រើក្នុងការរាជាអភិសេក, ទ្រង់ចុះស្រង់ព្រះគង្គាជាទឹកដ៏មានសព្វគុណស័ក្តិសិទ្ធិ ហើយស្តេចយាងចេញច្រត់ព្រះនង្គ័លដោយព្រះនង្គ័លមាស ទឹមគោឈ្មោលសម្បុរសមួយគូ ។ ឯព្រះនាងទ្រៅបទី ក៏យាត្រាតាមព្រះនង្គ័ល ព្រោះសាចបុព្វណ្ណជាតិ និងអបរណ្ណជាតិ គឺពូជធាគ្រប់ជំពូកដែលជារបរដំណាំក្នុងព្រះរាជាណាចក្រ ។ ពួកព្រាហ្មណ៍ក៏ស្វាធ្យាយស្លោកជ័យមន្តតាមគម្ពីរវេទ ។ ពួកស្រី ៗ ដែលមកក្នុងពិធីនេះ ក៏ស្រែកច្រៀងជាបទភ្លេងឲ្យពរជ័យ ។

នាកណ្តាលផ្ទៃទីបួនជ្រុងចតុរស្សនោះ គេសាងទីវេទកាមួយកម្ពស់អំពីដីមួយហត្ថ, លើព្រះទែនវេទិកានោះ មានឆ្លាក់រូបភាពសម្តែងទីតំណែង និងការត្រាច់ចរទៅនៃតារាករ ព្រមទាំងព្រះអាទិត្យព្រះច័ន្ទលើផ្ទៃមេឃ, នៅកណ្តាលព្រះទែននោះ មានតុបួនជ្រុងតូចមួយដាក់រំកាច់ខ្លឹមចន្ទន៍មួយគំនរ ហើយមានក្លស់មាសបើកបាំងពីលើ គេដុតខ្លឹមចន្ទន៍នោះហើយ យកប្រេងស្រូវសាលីនឹងវត្ថុដទៃ ៗ



ទៀតដែលស័ក្តិសិទ្ធិមកបង់ចុះក្នុងគំនរភ្លើងនោះ រួចភ្លើងក៏ឆេះរុងរោចន៍ឡើង ផ្សែងហុយគ្រឡុប់អប់ទាំងមណ្ឌលដ៏ស័ក្តិសិទ្ធិនោះ មានក្លិនក្រអូបឈ្ងុយឈ្ងប់ ។

ព្រះមហាក្សត្រិយ៍ទាំងពួង ព្រមទាំងព្រះរាជវង្សានុវង្សដែលចូលមកប្រជុំក្នុងពិធីនោះ មានចំនួន ៦៤ អង្គ នាំគ្នាយាងយាត្រាជាក្បួនទៅដងទឹកអំពីស្ទឹងព្រះគង្គាយកមកប្រោះព្រំលើព្រះសិរ នៃព្រះមហារាជយុធិស្ឋិរ តាមបទភ្លេង និងបទសូត្រមន្ត ។

លុះស្រេចកិច្ចខាងលើនេះហើយ គេក៏ប្រគេនទយ្យធម៌ទក្ខិណាទានដល់ពួកជីព្រាហ្មណ៍ និងចែកវត្ថុផ្សេង ៗ ដល់ពួកក្សត្រិយ៍បរទេសដែលនៅស្រុកចំណុះទាំងប៉ុន្មាន ។ មានក្សត្រិយ៍ជាច្រើនអង្គបានទទួលព្រះរាជទានរំយោលគ្រឿងយស ធ្វើពីរោមសត្វប្រដាប់ដោយពេជ្រ ប៊ុត និងមានទទួលគ្រឿងប្រដាប់យ៉ាងដទៃទៀតជាច្រើន ។ ឯអ្នកក្រៅពីពួកក្សត្រិយ៍នេះ បានទទួលព្រះរាជទានដំរី, សេះ, សំពត់អាវ និងគ្រឿងតាមសមគួរដល់ឋានៈរបស់ខ្លួន ៗ ។

បន្ទាប់ពីនោះមក គេយកសេះសដែលទុកបម្រុងនឹងសម្លាប់បូជាយ័ជនោះ ទៅលាងទឹកដ៏ស័ក្តិសិទ្ធិរួចស្រេចហើយ ទើបនាំយកទៅសម្លាប់ ។ ភីមកាន់ដាវធំវែងចុងស្រួច ឈរបង់ជំទែងកាប់កសេះនោះខ្ទាប់ដាច់ថ្មិល ។ មានន័យថា ក្បាលសេះនោះអន្តរធានបាត់ទៅមួយរំពេច មុខគួរឲ្យអស្ចារ្យណាស់ ហើយគេសំឡេះយកសាច់ដ៏

បរិសុទ្ធស័ក្តិសិទ្ធិបូជាភ្លើងពិធីនោះ ។

នៅមានពិធីយ៉ាងដទៃ ៗ តទៅទៀត ដែលមិនបានពោលទុកដោយល្អិតក្នុងទីនោះ សូមសង្ខេបសេចក្តី ហើយប្រាប់តែត្រឹមថា គេបានប្រព្រឹត្តយ៉ាងល្អិតល្អោចតាមសេចក្តីរាយការណ៍របស់កម្មវិធីក្នុងពិធីបូជានោះ ៗ ដែលច្បាប់ប្រាកដក្នុងគម្ពីរវេទ បានធ្វើសព្វគ្រប់ទាំងអស់ ជាការបង្កើតសេចក្តីល្អ ឬគោលសំខាន់ដល់ពិធីនោះ ទម្រាំតែគេរៀបចំសព្វគ្រប់អស់ វេលាជាងមួយសប្តាហ៍ គឺជាងមួយអាទិត្យ រហូតដល់ការជប់លៀងពួកជីព្រាហ្មណ៍ ជាទីបំផុតកិច្ចទាំងអម្បាលនេះ បើគេកាត់ចោលមិនធ្វើទៅវិញ ក៏នឹងបណ្តោយឲ្យខូចខុសពិធី ។ ភីមជាភ្នាក់ងារត្រួតត្រាមើលពិធីប៉ែកនេះ ដែលជាការកង្វល់អំពល់ធំច្រើន ឯការស្លដណ្តាំលៀងភ្ញៀវ រាប់ដោយពាន់ ៗ នាក់ ដែលអង្គុយទទួលទានអាហារក្នុងមួយពេល ៗ កាលបើស្រេចការលៀងភ្ញៀវសព្វគ្រប់ហើយ គេក៏ចែកប្រាក់ទក្ខិណាទានដល់ពួកជីព្រាហ្មណ៍ទាំងឡាយ លុះស្រេចភត្តកិច្ច និងការទទួលបច្ច័យហើយ ពួកព្រាហ្មណ៍ក៏ធ្វើភត្តានុមោទនា, ពួកភ្ញៀវរាប់ម៉ឺននាក់ក៏ថ្វាយស័ព្ទសាធុការពរទ្រហឹងអឹងកង ផ្សំគ្នាជាសម្លេងលាន់ឮរំពង ដូចកលស្ងួរលកទឹកក្នុងមហាសាគរ ។

រាជាណាចក្រហស្តិនបុរ បានត្រឡប់ចម្រើនរុងរឿងឡើងវិញ ដោយសាររដ្ឋបសាសនោបាយកោសល្យរបស់ព្រះមហារាជយុធិ-



ស្ឋិរ ។ សេចក្តីសុខ, មេត្តា, សត្យសុចរិត និងយុត្តិធម៌ បានត្រឡប់កើតមានឡើងក្នុងព្រះរាជាណាចក្ររបស់ព្រះអង្គវិញ ។ រាជមន្ទីរស្ថាននៅក្នុងឥន្ទ្របថដែលទ្រុឌទ្រោមបាក់បែកទៅ នៅវេលាដែលទ្រង់ត្រូវគេនិរទេសនោះ ក៏បានជួសជុលកសាងឡើងវិញជាថ្មី និងទ្រង់សាងព្រះរាជមន្ទីរស្ថានថែមថ្មីឡើងទៀតជាច្រើនខ្នងក្នុងទីផ្សេង ៗ ។

ចំណែកព្រះបាទធ្ឫតរាស្ត្រ គ្មានពេលណាឲ្យទ្រង់បានស្រាកស្រាន្តសេចក្តីសោយសោកពីរឿងមរណភាពនៃទុរយោធន៍ដ៏ជាបិយោរសរបស់ព្រះអង្គសោះ ។ ទោះបីទុរយោធន៍មានសេចក្តីខូចកាចខុសឆ្គងជាប់នៅក្នុងខ្លួនក្តី ក៏នៅតែជាឱរសសម្លាញ់របស់ព្រះអង្គមិនខានដែរ។ ឯព្រះបាទយុធិស្ឋិរបានប្រតិបត្តិព្រះមហារាជចាស់នេះដោយថ្នាក់ថ្នមយ៉ាងល្អបំផុត ទ្រង់តាំងព្រះអង្គក្នុងឋានៈជាបុត្រនៃមហារាជចាស់ និងខំបម្រើស្មើដូចទាសា មិនហ៊ានធ្វើតាមអំពើចិត្តខ្លួន ដោយមិនទាន់បានទទួលព្រះរាជានុញ្ញាត អំពីទ្រង់ជាមុនឡើយ ដើម្បីឲ្យទ្រង់ដែលមានបុត្រព្រាត់ប្រាសបាត់បង់ទៅនោះ បានសេចក្តីសុខព្រះកាយសប្បាយព្រះទ័យផង ។ ប៉ុន្តែជាការឥតអំពើព្រោះគ្មានអ្វីនឹងអាចកែប្រែបំបែរព្រះទ័យទ្រង់ ឲ្យកើតសប្បាយរីករាយក្នុងគ្រាទទួលទុក្ខដ៏ធំនេះឡើយ, គ្មានអ្វីយកមកសងជាបំណាច់រង្វាន់ជួសការខូចខាតដ៏ធំសម្បើម ដែលទ្រង់បានទទួលក្នុងបច្ឆិមវ័យនេះបានឡើយ, គ្មានកម្លាំងអ្វីមកជួយលើកស្ទួយសម្រាលទុក្ខដ៏ធ្ងន់

ក្នុងទ្រូងនេះ ឲ្យធូរស្រាលបានឡើយ ។ ដោយទ្រង់ចេះតែមានព្រះទ័យនឿយណាយក្នុងលោកខ្លាំងឡើង ទាល់តែគ្រឿងរាជកកុធភណ្ឌទាំងអស់ហាក់ដូចជាស្រមោលឥតខ្លឹមសារសោះ ។ ព្រះហឫទ័យទ្រង់ចង់បានសេចក្ដីសុខដ៏លើសលប់របស់មនុស្ស ព្រោះហេតុនោះក្នុងទីបំផុត ទ្រង់ក៏បានស្ដេចយាងចេញចាកអំពីពួកមនុស្សទៅគង់នៅក្នុងព្រៃជាមួយនឹងព្រះនាងគន្ធារីទេវី ទាំងវិទុរជាអ្នកប្រាជ្ញក៏បានតាមស្ដេចទៅផងដែរ ។ ព្រះមហារាជាយុធិស្ឋិរ និងខ្ញុំរាជការធំ ៗ បាននាំគ្នាជូនស្ដេច ព្រះរាជដំណើរទៅដល់ចុងព្រៃធំ ទើបព្រះមហារាជធ្ឫតរាស្ត្រ ត្រាស់ប្រាប់ឲ្យអ្នកទាំងនោះត្រឡប់វិលថ្កាននិវេសនដ្ឋានវិញ ទ្រង់នឹងត្រាស់លាដោយព្រះរាជសុន្ទរកថាដ៏ពីរោះក្បោះក្បាយដូចតទៅ ៖

«ម្នាលកូនសម្លាញ់អាពុកទាំងឡាយអើយ ! អ្នករាល់គ្នាក៏បានដឹងមកហើយដែរថា អាពុកនេះបានដោះខ្លួនចេញអំពីទុក្ខនៃក្សត្រិយ៍មកជាយូរឆ្នាំហើយ ហើយវៀរចាកភាពជាព្រះរាជា ហើយប្រគល់រាជ្យសម្បត្តិឲ្យបុត្ររបស់យើងដែលចែកឋានទៅ គឺទុរយោធន៍ ឥឡូវនេះ គេស្លាប់បាត់បង់ទៅ រាប់ជាផុតទុក្ខមួយលើកហើយ, គ្រានេះយើងមានចិត្តត្រេកអរក្នុងការនៅព្រៃ ប្រាសចាករាជ្យសម្បត្តិ យើងបានផ្ទុកផ្ដាក់រាជ្យសម្បត្តិឲ្យទៅក្នុងអារក្ខា នៃព្រះរាជាភាគិនេយ្យគឺយុធិស្ឋិរដែលទុកដូចជាបុត្ររបស់យើងម្នាក់, ឯខ្លួនយើងចាស់ជរា



ហើយប្រៀបគណនាដូចព្រឹក្សាជាតិនៅក្បែរមាត់ច្រាំង តែងទ្រុឌទ្រោមចុះតាមកាល លំបាកនឹងគ្រប់គ្រងរូបកាយដ៏ក្រំគ្រាដែលជិតនឹងចូលទៅក្នុងមាត់នៃមច្ចុរាជនេះពេកណាស់, ប្រការមួយទៀតព្រះជាម្ចាស់ក៏ហាក់តែមកបណ្ដាលឲ្យខ្ញុំចបង់ចក្ខុតាំងអំពីក្មេងហេតុនោះកាលពីដើមមក យើងមានតែភ្នែកខាងក្នុងប៉ុណ្ណោះ ជាមហាបុញ្ញលាភឲ្យយើងមើល ហើយសន្តោសធម៌ជាព្រៀយ ៗ, យើងយល់ឃើញថាគួរណាស់ហើយ ដែលយើងនឹងរក្សាអាយុ នៅសល់តិចតួចនេះ ដោយសេចក្ដីសន្តោសក្នុងរវៀងកាលដែលយើងកាន់កាប់ព្រះនគរ យើងបានឆ្លុតតម្រង់ទៅកាន់សេចក្ដីសុចរិតយុត្តិធម៌ តាមសតិបញ្ញា គ្រាន់តែឲ្យបានកេរ្តិ៍ឈ្មោះបន្តិចបន្តួចនឹងគេខ្លះដែរ ប៉ុន្តែមកប្រែខ្វៃជាខូចកេរ្តិ៍ឈ្មោះទៅ ព្រោះតែគ្រប់គ្រងនគរផ្ដេសផ្ដាសនៅគ្រាចុងក្រោយបំផុត ។ កូនអើយ ! អាពុកគិតក្រែងថា អំពើខុសនោះមានច្រើនមិនចង់ឲ្យអំពល់រវល់ដល់ចិត្តអ្នកជាកូន និងចិត្តអាពុក តទៅមុខ ដូចយ៉ាងបច្ចុប្បន្ននេះទៀត ប៉ុន្តែហេតុការណ៍ទាំងនោះជាអតីតភាគកន្លងហួសទៅហើយ, ម្នាលសុភាពបុរសទាំងឡាយអើយ ! កិច្ចការក្នុងកុរុអាណាចក្រនេះ វេលានេះយើងសូមផ្ញើទុកក្នុងអារក្ខារបស់អ្នកហើយ ជាភារៈរបស់អ្នកនឹងរក្សា ឬនឹងរំលាយចេញ ប៉ុន្តែចូរអ្នកចាំទុកឲ្យជាប់ថា មតិកដ៏ច្រើនទាំងម្លេះ ដែលយើងប្រគល់ឲ្យអ្នកនេះជាបរម្បរសម្បត្តិដ៏ត្រកាលសម្រាប់ព្រះនគរដ៏ឧត្តមស័ក្តិនេះ ជាបុព្វ-

កិច្ចខាងដើមដែលអ្នកត្រូវរក្សាទុកដោយសេចក្ដីហួងហែង និងការពារទុកដោយសេចក្ដីប្រយ័ត្នប្រយែងឲ្យណាស់ យើងសូមនិយាយរំឭកដាស់តឿនអ្នកក្នុងទីបំផុតនេះថា «ដរាបណា អ្នកជាម្ចាស់ផែនដីទ្រទ្រង់នូវធម៌ និងមានមេត្តាករុណាដល់ពួកមនុស្សផងគ្នា ដរាបនោះសឹកសត្រូវសូម្បីមានកម្លាំងខ្លាំងក្លាយ៉ាងណាក្ដី ក៏មិនអាចនឹងធ្វើអន្តរាយដល់សរសៃសក់នៃអ្នកបានឡើយ» ។

ព្រះមហារាជយុធិស្ឋិរ ក្រាបចុះទៀបយុគលបាទនៃព្រះមហារាជធ្មតរាស្ត្រដោយគោរព ទទួលព្រះពរតម្កល់ទុកលើត្បូង ហើយក៏ក្រាបថ្វាយបង្គំលាត្រឡប់មកក្រុងហាស្ដិនបុរវិញ ។

លំដាប់អំពីនោះមក ព្រះមហារាជយុធិស្ឋិរ បានគ្រប់គ្រងសិរីរាជ្យសម្បត្តិ រាជសន្តតិវង្សជាសុខក្សេមក្សាន្ត ល្បីល្បាញព្រះកិត្តិយសខ្ពស់ត្រដែតត្រដឹមដល់សកលលោក ឲ្យឃើញជាក់ច្បាស់ថាព្រះអង្គជាអ្នកគ្រប់គ្រងរាជ្យ ដោយទសពិធរាជធម៌ និងប្រកបដោយមេត្តាករុណាជាបុរេចារិក ។ អ្នកនគរនាំគ្នាជ្រះថ្លាស្រឡាញ់ អស់អញភក្តិ ទាំងគោរពកោតក្រែងព្រះចេស្ដាបារមីជាអាចិណ្ណ, អរិរាជសត្រូវស្ញប់ស្ញែងក្រែងព្រះតេជានុភាព, ពួកអ្នកប្រទេសជិតខាងក៏នាំគ្នាស្រឡាញ់រាប់អាន ។ ព្រះឥរិយាបថខាងក្រៅ ប្រព្រឹត្តទៅតាមយសស័ក្តិ និងនាទីនៃក្សត្រិយ៍ពិតប្រាកដ ប៉ុន្តែឯខាងក្នុងព្រះហឫទ័យធ្ងន់ទៅដោយធិមិសន្តោស សព្វព្រះហឫទ័យតែក្នុងការនៅព្រៃ ទ្រង់



គិតហើយគិតទៀតដល់កាល ១៣ ឆ្នាំ ដែលទ្រង់បានប្រព្រឹត្តរួចមកហើយ ដោយឋានៈជាអ្នកត្រូវទោសនិរទេសគ្មានទីសំណាក់អាស្រ័យ ទ្រង់ធ្លាប់បានជ្រាបរួចមកហើយថា អារញ្ញប្រទេសដែនដងព្រៃមានម្លប់ត្រឈឹងត្រឈៃ ត្រជាក់សាយសព្វអស់ឥន្ទ្រិយ៍ មានអាកាសធាតុដ៏បរិសុទ្ធ ជាទីឲ្យល្ហែល្ហើយស្បើយស្រួលក្នុងឱរា ចិញ្ចឹមជីវិតដោយផលាផលនិងមើមឈើ ដូចយ៉ាងអារញ្ញិកសត្វ, សេចក្ដីកើតអំពីការស្ងប់ស្ងាត់ ដ្បិតគ្មានអ្នកណាមករំអុកចិត្តឲ្យចង្អៀតចង្អល់ ដែលទ្រង់ធ្លាប់បានជួបប្រទះរួចមកហើយ ក្នុងរវាងនៅព្រៃ ១៣ ឆ្នាំនោះ ទ្រង់តែងលើកយកមកប្រៀបធៀបក្នុងបច្ចុប្បន្ននេះជាញយ ៗ, ក្នុងព្រះចិន្តាឃើញថា ជាវេលាសុខសប្បាយបំផុតក្នុងអាយុកាល ព្រះអធ្យាស្រ័យនៃទ្រង់ធ្ងន់ទៅក្នុងការនៅព្រៃក៏មែនពិតហើយ ប៉ុន្តែមិនមែនជាទ្រង់ភ្លេចរឿងទុក្ខសោកដល់ពពួកព្រះញាតិ ដែលត្រូវពិឃាតស្លាប់បង់ក្នុងសង្គ្រាមនោះទេ ទ្រង់សោយសោកឥតល្ហែដល់វិញ្ញាណដែលព្រាត់ប្រាសទៅទាំងកំពុងស្រឡាញ់ពេញចិត្ត ឥតលស់មួយវេលា ទ្រង់នឹកស្ដាយថា បើប្រសិនណាជាមិនកើតចម្បាំងរាំងជល់ទេ មុខជានឹងបានឃើញមុខព្រះញាតិនៅរហង់ ជុំវិញព្រះអង្គត្រៀបត្រាធ្វើឲ្យអគារស្ថាន និងអាណាចក្រអធិកធមឈូឆះជាទីសប្បាយរីករាយ, ទុក្ខថ្មីសោតក៏ផ្ទុកផ្ទួនធ្ងួនត្រួតមកលើទៀត ផុតវិស័យនឹងឆ្លាក់ឆ្លៀតឲ្យស្រន់ស្រាល ដោយហេតុកាលក្រោយអំពីព្រះបាទធ្មតរាស្ត្រឃ្លាត

បាត់ទៅ ២ ឆ្នាំ នារទអ្នកប្រាជ្ញបាននាំព័ត៌មានមកក្រាបទូលថា «មានភ្លើងឆេះព្រៃ, ព្រះបាទធ្ឫតរាស្ត្រ ទ្រង់ព្រះជរាព្រះនេត្រអន្ធការ និងព្រះនាងគន្ធារី ព្រមទាំងអ្នកដែលនៅជាមួយស្តេច ត្រូវភ្លើងព្រៃឆេះពោលស្លាប់អស់ទៅហើយ មុខគួរឲ្យអនិច្ចាអ្វីម្ល៉េះទេ ! ចំណែកអ្នកធ្វើសង្គ្រាមក៏ស្លាប់ក្នុងសង្គ្រាម ពួកអ្នកមិនធ្វើសង្គ្រាមក៏ស្លាប់ក្រៅសង្គ្រាមដែរ»។

បន្ទាប់អំពីព័ត៌មាននេះមក នៅមានព័ត៌មានថ្មីមកដល់ទៀត គឺមានរាជទូតនាំដំណឹងមកអំពីក្រុងទ្វារកៈ មកក្រាបទូលថា «ក្រឹស្ណៈឲ្យអញ្ជើញអរជុនទៅក្រុងទ្វារកៈជាប្រញាប់» ។ អរជុនក៏ប្រញាប់ប្រញាល់ទៅក្រុងទ្វារកៈ ប៉ុន្តែមុននឹងទៅដល់ក្រុងនេះ ក្រឹស្ណៈក៏ទទួលទិវង្គតផុតបាសទៅ ។ អរជុនទៅដល់ហើយ នឹងវិលត្រឡប់មកវិញភ្លាមមិនកើត ត្រូវនៅជួយមើលត្រួតត្រាដល់ការឈាបនកិច្ចសពព្រះរាជសម្ព័ន្ធមិត្រដ៏ស្និទ្ធរបស់ទ្រង់ឲ្យស្រេចការសិន ។

ព្រះពលរាមជាព្រះអនុជនៃក្រឹស្ណៈ ក៏ទិវង្គតទៅតាមក្រឹស្ណៈដែរជាបន្ទាន់បន្ទាប់គ្នា ។ ព្រះបាទវាសុទេព ព្រះរាជបិតានៃក្រឹស្ណៈក៏ទិវង្គតក្រោយនោះបន្តបន្ទាប់គ្នាដែរ ។ មិនតែប៉ុណ្ណោះ ក្នុងកាលមិនយូរប៉ុន្មាន អំពីវេលដែលអរជុនត្រឡប់អំពីក្រុងទ្វារកៈមកវិញហើយ ទឹកសមុទ្រជោរជន់ឡើងលិចក្រុងជាស្រុកមាត់កំពង់របស់វង្សយាទ-វៈ លិចអន្តរធានអស់ទៅ ។



កាលអរជុននាំព័ត៌មានមរណៈនៃក្រឹស្ណៈ និងសេចក្តីវិនាសសាបសូន្យនៃយាទវៈអាណាចក្រ មកក្រាបទូលនោះ សេចក្តីសោយសោករបស់ព្រះបាទយុធិស្ឋិរ រឹតតែទ្វេច្រើន ៗ ឡើង រកទីបំផុតគ្មានរឹតរួតព្រះហឫទ័យងងឹតឈឹង ឥតអ្វីមកកំចាត់ឲ្យឃ្លាតចេញបានឡើយ ទ្រង់ធុញទ្រាន់នឿយណាយនឹងសាច់ស្បែក រាងកាយដ៏ជាភារៈយ៉ាងធ្ងន់ មានព្រះរាជបំណងតែនឹងលះបង់គ្រឿងរឹតរូតទាំងនេះចេញ និងលះបង់ជីវិតដែលជាគ្រឿងកង្វល់ធំនេះចោល ទ្រង់មានព្រះហឫទ័យនឹកមមៃ គ្មានដាច់មួយវេលា ទ្រង់នឹកសង្ឃឹមតែលើព្រះអនុជទាំង ៤ អង្គ និងផ្ទុកផ្តាក់ឲ្យជាអ្នកតំណាងព្រះអង្គតទៅហើយនិងចង់បានការអនុមតិអំពីព្រះអនុជទៅនៅព្រៃ ធ្វើឲ្យដូចជាបព្វជិតប្រព្រឹតវត្ត ញុំាងកាលឲ្យកន្លងរំលងទៅ ដោយការចម្រើនមេត្តាភាវនា ។ ព្រះអនុជទាំង ៤ អង្គ ក៏អនុមតិអនុមោទនាតាមព្រះរាជប្រារព្ធ ។ ប៉ុន្តែព្រះអនុជទាំង ៤ អង្គ ក៏មានបំណងដូចគ្នានឹងព្រះជេដ្ឋាដែរ កើតព្រះទ័យនឿយណាយក្នុងរាងកាយ និងសេចក្តីលំបាកលំបិននៃជីវិត ចង់ស្វែងរកតែសេចក្តីសុខដើម្បីសម្រាកកាយឲ្យបានសប្បាយដោយសន្តិវិធី ទើបប្រុងប្រៀបខ្លួនទុកជាស្រេច ចាំតាមស្តេចទៅនៅព្រៃជាមួយផងដែរ ដោយគ្មានព្រះទ័យនឹកស្រណោះអាឡោះអាល័យនឹងសម្បត្តិសម្បូណ៌ហូរហៀរនោះសោះឡើយ ។

ព្រះមហារាជយុធិស្ឋិរ ក៏បែងចែករាជអាណាចក្រហាស្តិនបុរជា

ពីរភាគ មួយភាគទ្រង់លើកឲ្យប្រីក្សិត បុត្រអភិមន្យុ ដែលប្រសូត្រក្រោយការមរណៈនៃអភិមន្យុ ទ្រង់អភិសេកឲ្យជាក្សត្រិយ៍គ្រប់គ្រងពិភពហាស្តិនបុរ មួយភាគទៀត ប្រទានឲ្យយុយុត្សុជាបុត្រប្អូនទុរយោធន៍ ទ្រង់អភិសេកឲ្យជាព្រះរាជាគ្រងក្រុងឥន្ទ្របថ និងទ្រង់ប្រទានឱវាទផ្តែផ្តាំប្រដៅស្តេចថ្មីទាំងពីរអង្គ ឲ្យរក្សាសន្តិភាព និងសម្ព័ន្ធមេត្រី ព្រមទាំងទសពិធរាជធម៌ ។

គ្រានោះ ក្សត្រិយ៍បាណ្ឌពដោះគ្រឿងប្រដាប់សម្រាប់ក្សត្រិយ៍ចេញអស់ពីអង្គ, លះបង់គ្រឿងមាសពេជ្រ និងអាវុធយុទ្ធភ័ណ្ឌ ហើយទ្រង់ភេទបព្វជិតតាមលទ្ធិសម័យនាំយកទាំងព្រះនាងទ្រៅបទីទៅជាមួយផង ចរចេញយាត្រាឆ្ពោះទៅកាន់ព្រៃ មានទាំងសុវានសត្វ (ឆ្កែ) ដ៏ស្លូតត្រង់នឹងម្ចាស់មួយតាមទៅផង ដែលវាមិនព្រមឲ្យទុកចោលវានៅព្រះរាជវាំង ទ្រង់យាងឆ្ពោះសំដៅទៅទិសបូព៌ មួយថ្ងៃហើយមួយថ្ងៃទៀត, មួយអាទិត្យហើយមួយអាទិត្យទៀត ស្តេចព្រះរាជដំណើរទៅក្នុងព្រៃធំដ៏ងងឹត ជួនកាលត្រូវយាងកាត់វាលហាលថ្ងៃលំបាករហោមរហាមដូចជាអណ្តើកចូលភ្លើង, ជួនកាលត្រូវឆ្លងស្ទឹងដែលមាននៅទទឹងមុខ ក្នុងរវាងចន្លោះផ្លូវ ទ្រង់ចេញចោលសម្បុកសម្បត្តិទៅ ដោយតាំងព្រះទ័យថា នឹងលែងវិលត្រឡប់ថយក្រោយវិញនាំគ្នារត់ចោលគ្រឿងកង្វល់ និងសេចក្តីនឿយណាយនៃជីវិត ។ ការលំបាកគោកយាកទៅតាមផ្លូវ ការក្រវល់ក្រវាយដោយសេចក្តី



ស្រេកឃ្លាន មុខគួរឲ្យមានទុក្ខវេទនាណាស់ ប៉ុន្តែទ្រង់ព្រមទទួលទុក្ខវេទនានោះដោយតុណ្ហីភាពឥតរួញរា ។ ការដែលទ្រង់ខំធ្វើទៅទាំងនេះ ដោយមានបំណងដើម្បីនឹងឲ្យផុតស្រឡះពីគ្រឿងរួបរឹតនៃជីវិត ។

កាលកន្លងទៅមិនជាយូរប៉ុន្មានថ្ងៃ នាងទ្រៅបទីដែលជាស្ត្រីភាពមានកម្លាំងតិចខ្សោយជាងគេក្នុងពួកនោះ ក៏ដួលដេកតាមផ្លូវដាច់ខ្យល់ស្លាប់ដោយមហន្តទុក្ខដូចពោលហើយ ។ គ្មានការយំយែកដែលជាសញ្ញាសម្តែងសេចក្តីអាឡោះអាល័យដល់នាងទេ ។ ចំពោះខ្លួននាងវិញ ចាត់ថាអស់ទុក្ខសោកពោគភ័យមួយលើកហើយ, អស់កិច្ចអំពល់ខ្វល់មួយគ្រាហើយ ។ កាលនាងទ្រៅបទីស្លាប់ទៅហើយភីមទូលសួរយុធិស្ឋិរ ថា «ហេតុអ្វីបានជានាងទ្រៅបទីស្លាប់ ហេតុអ្វីបានជានាងមិនទៅឡើងស្ថានសួគ៌ទាំងរស់ ? បានជាមកទទួលមរណកម្មនៅកណ្តាលផ្លូវដូច្នេះ ? » ។

ប្រស្នាទាំងនេះ មិនបាននិយាយក្នុងលំអាននៃអ្នកសោយទុក្ខវេទនាទេ និយាយក្នុងលំអាននៃផ្លូវធម្មប្រស្នា ។ យុធិស្ឋិរឆ្លើយថា «ហឫទ័យរបស់នាង និងជីវិតរបស់នាងរួមជាប់ជាមួយគ្នានឹងអរជុន, កាលអរជុនបានប្រព្រឹត្តកន្លងអកុសលកម្មហើយ នាងក៏បានកន្លងអកុសលកម្មផងដែរ បានជានាងត្រូវតែទទួលផលនៃអកុសលកម្មដូច្នេះ» ។

ខាងក្រោយមក បងប្អូនភ្លោះមួយគូ គឺនកុល និងសហទេព ដួលដាច់ខ្យល់ស្លាប់តាមផ្លូវទៅ ។ ឯអ្នកដែលសល់នៅ ក៏នាំគ្នាដើរតទៅមុខទៀត ហាក់ដូចជាឥតដឹងថាមានហេតុអ្វីកើតឡើង ក្នុងក្រុមខ្លួនសោះ បីដូចជាបានកំណត់គ្រោងការទុកជាស្រេចមកអំពីដើមហើយ ។

ចំណេរមក អរជុនស្លាប់ទៅទៀត ភីមមានចិត្តតក់ស្លុតរន្ធត់នឹកស្រៀវក្នុងហឫទ័យបន្តិចបន្តួចខ្លះដែរ ទើបទូលសួរយុធិស្ឋិរថា «ហេតុអ្វីអរជុន អ្នកឥតខុសសោះ ក៏មកទទួលវិបាកនៃបាបកម្ម គឺមរណៈដែរ ?» ។

យុធិស្ឋិរឆ្លើយថា «ហេតុគ្រាមួយនោះ អរជុនបានអួតថ្វីដៃរបស់ខ្លួនហួសប្រមាណថា «ខ្លួននឹងប្រហារសឹកសត្រូវរបស់ខ្លួនឲ្យរាបទាបបរាជ័យអស់ទៅ ដោយការចូលវាយតែមួយលើក, រឿងនេះ អរជុនមិនអាចនឹងធ្វើឲ្យសម្រេចតាមពាក្យប្ដេជ្ញារបស់ខ្លួន បានសំដីដែលអួតនោះក្លាយទៅជាមុសាវាទ, ឯមុសាវាទនោះជាតួបាប ផលនៃបាបនេះ គឺមរណៈ»។

ភីម និងយុធិស្ឋិរតែពីរអង្គប៉ុណ្ណោះ ដែលសល់នៅក្នុងវេលានេះ ទ្រង់នាំគ្នាដើរផ្លូវតទៅមុខ ចេះតែដើរស្ងាត់ស្ងៀមឈឹង គ្មាននិយាយសន្ទនាគ្នារឿងអ្វីសោះ ។ ឯសុវានសត្វនោះ ក៏តែងជិតដោយតាមក្រោយទៅដូចអំពីដើម ។ ថ្ងៃមួយនោះ ភីមទ្រាំនឹងសេចក្ដីនឿយ



ហត់ទុក្ខលំបាកពុំបាន ក៏ដួលដាច់ខ្យល់ស្លាប់ទៅទៀត ប៉ុន្តែនៅវេលាហប ៗ ជិតដាច់ខ្យល់នោះ ភីមបានទូលសួរយុធិស្ឋិរថា «ទ្រង់ជ្រាបបានឬទេថា ព្រោះអកុសលកម្មអ្វី បានជាទូលបង្គំមកគប់ប្រសព្វនឹងមរណៈក្នុងវេលានេះ ?»

យុធិស្ឋិរ តបថា អ្នកបានធ្វើអំពើបាបក្នុងកាយទ្វារ មិនមែនក្នុងវចីទ្វារទេ អ្នកប្រឡាក់ប្រឡូសទៅដោយនិស្ស័យជាអ្នកត្រគោះអសុពោះ ដេរពោលអ្នកដទៃ, លោភអាហារ និងនិយាយអួតខ្លួន» ។

ក្នុងវេលានេះ នៅសល់តែយុធិស្ឋិរ មួយអង្គ ស្ដេចយាងសន្សឹម ៗ ទៅមុខទៀត គ្មានគ្នីគ្នា នឹងសន្ទនាជាពីរទេ មានតែសុនខមួយជាមិត្រភក្តិដើរតាមទៅក្នុងដែនដងព្រៃអស់រយៈកាលជាយូរថ្ងៃ ទើបស្ដេចទៅដល់មេរុបពិត គ្រាទៅដល់ហើយ ទ្រង់បានឮសម្លេងព្រះឥន្ទ្រស្រែកប្រាប់ថា «ឡើងមកកាន់ស្ថានសួគ៌ចុះ ក្សត្រិយ៍ទ្រង់ធម៌» ប៉ុន្តែយុធិស្ឋិរឆ្លើយថា «មិនបាន ខ្ញុំទៅតែម្នាក់ឯងមិនបានទេ ចូរព្រះអង្គអនុញ្ញាតឲ្យប្អូន ៗ ខ្ញុំ និងនាងទ្រៅបទីដែលខ្ញុំបោះបង់ចោលតាមផ្លូវមកនោះទៅជាមួយផង ដ្បិតគេទាំងនោះជាអ្នកមានសច្ចៈ និងមានយសស័ក្តិខ្ពង់ខ្ពស់ក្នុងជីវិតរបស់គេ ដូចគ្នានឹងខ្ញុំដែរ, ចូរស្ដាប់ខ្ញុំព្រះឥន្ទ្រអើយ ! ចូរឲ្យបានសម្រេចតាមពាក្យអង្វររបស់ខ្ញុំ»។

ព្រះឥន្ទ្រឆ្លើយប្រាប់ពីលើមកថា «បងប្អូននឹងរាជិនីរបស់ទ្រង់ឡើងមកមុនទ្រង់រួចហើយ»។ យុធិស្ឋិរតបថា «បើដូច្នោះ ខ្ញុំអនុញ្ញាត

ឲ្យសុនខកំសត់របស់ខ្ញុំ ឡើងទៅកាន់ស្ថានសួគ៌ផង ព្រោះវាបានជាប់តាមខ្ញុំមករហូតជីវិតរបស់វា»។ ព្រះឥន្ទ្រមានទេវឱង្ការថា «ស្ថានសួគ៌មិនមែនជាស្ថានសម្រាប់សត្វលាមកនឹងឡើងមកបានទេ»។យុធិស្ឋិរអង្វរថា «ទ្រង់នឹងសប្បាយព្រះហឫទ័យមិនកើតទេ ព្រោះសុនខនេះឡើងទៅផងមិនបាន, ព្រោះហេតុអ្វី ? ព្រោះហេតុថាវាជាសត្វស្លូតត្រង់ ហើយភក្ដីនឹងខ្ញុំជាទីបំផុត វាបានខំតាមខ្ញុំមកជាមិត្រកំសត់រហូតដល់អស់ជីវិតរបស់វា»។

ព្រះឥន្ទ្រ ៖ «ទ្រង់បានលះបង់ចោលព្រះអនុជ និងមហេសីរបស់ទ្រង់ក្នុងគ្រាដើរផ្លូវដែលអស់ជើងគ្មានកម្លាំងស្លាប់កណ្ដាលផ្លូវម្នាក់ម្ដង ៗ នោះ ដោយឥតអាឡោះអាល័យដល់គេបន្តិចសោះ ចុះហេតុម្ដេចក៏ទ្រង់បោះបង់សុនខលាមកមិនដាច់ហាំះ ?» ។ យុធិស្ឋិរអធិប្បាយថា «ខ្ញុំគ្មានចេតនាប៉ុនប៉ងនឹងលះបង់អ្នកដែលស្លាប់ទាំងនោះទេ ប៉ុន្តែអ្នកអស់នោះនឹងត្រឡប់រស់ឡើងវិញមិនបាន ខ្ញុំក៏ត្រូវកាត់ចិត្តដើរចោលគេមក ដោយហេតុទាល់គំនិតប្រាជ្ញា មិនដឹងបើនឹងគិតកែខៃទៅផ្លូវណាទៀត, ចំណែកសត្វនេះ វាកំពុងនៅមានជីវិតរស់នៅឡើយ សឹងដេកនៅក្បែរខាងខ្ញុំនេះ ហេតុនោះ ខ្ញុំនឹងកាត់ចិត្តចោលវាម្ដេចបាន» ត្រាស់ដូច្នេះហើយយុធិស្ឋិរ ក៏ងាកទៅទតរកសុនខនោះ ស្រាប់តែបាត់វាទៅ ។ ព្រះធម្មទេព (ទេវតាអ្នករក្សានូវយុត្តិធម៌) គឺព្រះឥន្ទ្រនៅឈរត្រង់កន្លែងសុនខដេកនោះ ហើយ



ត្រាស់នឹងយុធិស្ឋិរថា «នែយុធិស្ឋិរ! ខ្លួនអ្នកជាបុត្ររបស់យើង ជាអ្នកមានសច្ចៈរហូតអស់ជីវិតរបស់អ្នក ទៀងទាត់មិនដែលឃ្លៀងឃ្លាតអ្នកមិនព្រមលះបង់ចោលយើងដែលជាសុនខរបស់អ្នក ព្រោះថាយើងជាអ្នកមានសត្យសុចរិតស្លូតត្រង់នឹងអ្នក, អ្នកឯងជាមនុស្សរកអ្នកណាប្រៀបគ្មានក្នុងសកលលោក» ។

គ្រានោះ ព្រះចោមទេពក៏នាំយុធិស្ឋិរ ឡើងកាន់ស្ថានសួគ៌ទាំងរស់ ។ កាលយុធិស្ឋិរយាងទៅដល់ បានឃើញទុរយោធន៍ គង់លើរាជបល្ល័ង្កដ៏រុងរឿងច្រាលរន្ទាល មានពួកក្សត្រិយ៍កុរុអ្នកធំ ៗ ដែលត្រូវអាវុធស្លាប់ក្នុងសង្គ្រាមនោះ ឈរអមជុំវិញរាជបល្ល័ង្ក ទ្រង់ទតរូបក្សត្រិយ៍នោះ ៗ ដោយនឹកស្ងើចអស្ចារ្យ ហើយទតរឿង ៗ តទៀតមិនប្រទះឃើញព្រះអនុជ និងនាងទ្រៅបទីរបស់ព្រះអង្គនៅក្នុងកម្លុងនោះសោះ ទ្រង់ចេះតែនឹកពិភាល់ឆ្ងល់ក្នុងចិន្តាណាស់ ។ ព្រះឥន្ទ្រទ្រង់ជ្រាបវារៈព្រះទ័យនៃយុធិស្ឋិរ ហើយត្រាស់ថា «អ្នកនឹកឆ្ងល់ថាហេតុម្ដេចបានជាមិនប្រទះឃើញព្រះអនុជ និងមហេសីក្នុងទេវលោកនេះ ? ល្អហើយ យើងនឹងប្រាប់អ្នកឯងឲ្យយល់ច្បាស់ថា គេជាសត្វបាប ហេតុនោះ គេនឹងឡើងមកក្នុងទីនេះមិនបានជាដាច់ខាត, ពេលនេះគេនៅក្នុងទីដទៃនៅឡើយ អ្នកត្រូវនៅឃ្លាតឲ្យឆ្ងាយអំពីគេអ្នកត្រូវសោយសុខក្នុងស្ថានសួគ៌ ចំពោះខ្លួនតែម្នាក់ឯងចុះ ចោលអ្នកទាំងនោះឲ្យនៅរងកម្មទ្រាំទុក្ខវេទនា ដែលគេត្រូវទទួលតាម

យថាកម្មរបស់គេចុះ»។

ចំណែក យុធិស្ឋិរគ្មានប្រាថ្នានឹងនៅឆ្ងាយអំពីព្រះរាជភាតា និង មហេសី ហើយគង់នៅតែមួយអង្គឯងក្នុងសំណាក់នៃព្រះឥន្ទ្រដ៏ជាស្ថានបរមសុខនោះឡើយ ទើបទូលទាស់ថា «ខ្ញុំនឹងនៅជាមួយពួកគោរពក្នុងស្ថានសួគ៌នេះមិនបានទេ ខ្ញុំនៅចង់រួមជាមួយបងប្អូន និងមហេសីរបសខ្ញុំជាង ទោះគេទៅនៅក្នុងទីកន្លែងណាក៏ដោយ ខ្ញុំនឹងចោលគេជាអ្នកមានចិត្តស្នេហាចងជាប់ជានិច្ច ដោយគិតឲ្យតែបានសុខម្នាក់ឯងនោះមិនកើតសោះឡើយ»។

ព្រះឥន្ទ្រមានទេវឱង្ការសួរដោយខ្ងាល់ថា «អ្នកឯងប្រុងប្រៀបខ្លួនទុកជាស្រេចហើយឬ ? ដែលនឹងទៅនៅរងទុក្ខក្នុងអបាយភូមិនោះ ព្រោះតែសេចក្ដីស្នេហាដល់គេទាំងឡាយ ?» ។

យុធិស្ឋិរ «សេចក្ដីស្រឡាញ់នេះឯងហើយ នឹងបណ្ដាលសាហ័សកម្មទាំងនោះ ដែលគេកំពុងតែសោយ ឲ្យត្រឡប់ក្លាយជាបរមសុខវិញ សូមឲ្យខ្ញុំទៅនៅឯទីកន្លែងដែលបងប្អូនខ្ញុំនៅ និងដែលទ្រៅបទីនៅ ខ្ញុំនឹងលះបង់ចោលគេម្ដេចកើត»។

គ្រានោះ ព្រះឥន្ទ្រត្រាស់បញ្ជាឲ្យទេពបរិពារមួយអង្គនាំយុធិ-ស្ឋិរ ទៅកាន់ទីសំណាក់នៃវិញ្ញាណក្ខន្ធរបស់ពួកក្សត្រិយ៍បាណ្ឌព ។ ទេវទូតនោះនាំយុធិស្ឋិរទៅកាន់ស្រុកក្រោមព្រះធរណី ដ៏ឆ្ងាយសែនឆ្ងាយ ដ៏ជ្រៅហើយជ្រៅចុះទៅទៀតតាមលំដាប់ ។ ទីនោះមាន



អាកាសងងឹតសូន្យសុង, អាកាសពេញទៅដោយផ្សែងផ្សា ។ សត្វដែលមានខ្យល់ប្រាណនឹងដកដង្ហើមចេញចូលមិនស្រួល ចេះតែឈ្លក់ ។ ផ្លូវថ្លាក្រាលរាយទៅដោយរងើកភ្លើង មានលលាដ៏ក្បាលខ្មោចរៀបរៀងរាយជាកំពែងខែត្រខ័ណ្ឌ, ឯលលាដ៏ក្បាលខ្មោចប្រេតទាំងនោះចេះតែស្រែកថ្ងូរហ៊ោ ៗ តាមស័ព្ទប្រេតវិស័យ ។ នៅទីកណ្ដាលភូមិមានរណ្ដៅយ៉ាងធំសម្បើម មានភ្លើងឆេះសន្ធោសន្ធៅ ។ ឯក្នុងរណ្ដៅភ្លើងនោះ ក្សត្រិយ៍បាណ្ឌពភាតា និងទ្រៅបទីកំពុងតែសោយកម្មវិបាកបម្រះនឿលអន្ទះអន្ទែង ស្រែកទ្រហោយំទ្រហឹងអឺងកងដោយសេចក្ដីឈឺចាប់ក្ដៅពោលរាល ព្រោះអំណាចកំដៅនៃភ្លើងអវិចីដែលឆេះមិនចេះរលត់នោះ ។

យុធិស្ឋិរទតឃើញអាការដូច្នោះហើយ ក៏ភ្ញាក់ខ្លួនព្រឺត ហើយថយក្រោយក្រាក ឃ្លាតចេញមកដោយភិតភ័យតក់ស្លុត ។

ក្សិណនោះ ទ្រង់បានឮសម្លេងព្រះអនុជ និងទ្រៅបទីស្រែកអង្វរសុំឲ្យទ្រង់ឈប់បង្អង់មួយស្របក់សិន ព្រោះថាដែលបានទ្រង់មកគង់នៅ ១ ទីនោះ ធ្វើឲ្យគេបានសេចក្ដីសុខស្បើយទុក្ខស្រាកស្រាន្តគ្រាន់បើ ។ យុធិស្ឋិរ សូម្បីមានសេចក្ដីខ្លាចភ្លើងនរកនោះជាពន្លឹកក្រែងទ្រង់នឹងត្រូវទទួលរងដូចយ៉ាងគេដែរ តាមដែលទ្រង់ឃើញក្នុងវេលានោះ ប៉ុន្តែដោយអំណាចនៃមេត្តាចិត្ត ទ្រង់នឹងបៀសចេញចោលអ្នកទាំងនោះមិនបាន ត្រូវតែគង់នៅកំដរសត្វនរកទាំង

នោះឲ្យបានស្រាកស្រាន្តទុក្ខវេទនាមួយគ្រាសិនហើយទ្រង់បណ្តេញទេវបុត្រ អ្នកនាំផ្លូវមកនោះថា «អ្នកចៀសចេញអំពីខ្ញុំបានហើយក្នុងវេលានេះ ផ្សិតខ្ញុំនឹងនៅក្នុងទីនេះសិន ដើម្បីនឹងជួយរម្ងាប់ទុក្ខផ្សាខ្លោចរបស់បងប្អូន និងប្រពន្ធនៃខ្ញុំ» ។

ក្នុងមួយរំពេចនោះ ការផ្លាស់ប្រែយ៉ាងអស្ចារ្យបានកើតឡើងប្រែរូបភាពដើមចេញបាត់អស់ ។ មនុស្សក្នុងសកលលោក បើបានឃើញទីនោះហើយ ស្ទើរតែនឹងមិនជឿភ្នែករបស់ខ្លួនឯង ព្រោះទីដែលងងឹតសូន្យសុង និងទីដែលសត្វសោយមហាវិបាកនោះ បានត្រឡប់ប្រែក្លាយជាភ្លឺស្វាងរុងរឿង និងជាទីសុខសប្បាយពន់ប្រមាណទៅវិញ ។

ឯភូមិនរកដែលយុធិស្ឋិរឃើញនឹងព្រះនេត្ររបស់ទ្រង់ក្នុងមួយរំពេចនោះ គ្រាន់តែជាស្រមោលដែលព្រះឥន្ទ្រនិម្មិត បណ្តាលឲ្យឃើញប៉ុណ្ណោះ ដើម្បីនឹងពិសោធន៍សេចក្តីសត្យសុចរិត និងសេចក្តីមេត្តាស្នេហារបស់ទ្រង់ បើសេចក្តីសត្យសុចរិត និងមេត្តាចិត្តរបស់ទ្រង់បានឈ្នះការពិសោធន៍ជាយ៉ាងពន្លឹកដូច្នោះហើយ ទេវតាក៏នាំទ្រង់ទៅឯទឹកព្រះគង្គា សឹងហូរដោយដងស្ទឹងនៅលើស្ថានសួគ៌ជាទឹកមានអានុភាពដ៏ស័ក្តិសិទ្ធិ ឲ្យទ្រង់ចុះស្រង់ទឹកនោះ ។ ដោយអានុភាពនៃទឹកព្រះគង្គា ដ៏ស័ក្តិសិទ្ធិឆុតឆាប់នោះ ព្រះវរកាយនៃយុធិស្ឋិរក៏ប្រែក្លាយទៅជាទេវសភាពទិព្វរូប កាលបើក្លាយទៅជា



ទេព្តាហើយ ទ្រង់ក៏បានអនុញ្ញាតឲ្យគង់នៅក្នុងស្ថានសួគ៌ជាន់ខ្ពស់ ។ ឯព្រះក្រឹស្ណៈជាព្រះរាជសម្ពន្ធមិត្ររបស់ទ្រង់ ដែលបានឡើងទៅឧប្បត្តិមុន ក៏ធ្វើបដិសណ្ឋារទទាក់ទទួលយ៉ាងរីករាយ ។

ចំណែកព្រះក្រឹស្ណៈនោះ មានរស្មីភ្លឺផ្លេករុងរឿងជាបំផុត គ្របលើរបស់ទាំងពួងដែលរុងរឿងក្នុងលោក សឹងភ្នែករបស់មនុស្សមិនដែលបានឃើញតាំងពីកាលណា ៗ មក ។

គ្រានោះ យុធិស្ឋិរបានទតឃើញព្រះអនុជទាំង ៤អង្គ ព្រមទាំងទ្រៅបទីទេពីរបស់ទ្រង់ និងបណ្តាអ្នកដែលទ្រង់ស្រឡាញ់រាប់អានកាលនៅក្នុងមនុស្សលោកនោះផងដែរ ៕

សិទ្ធិរស្តុ

រឿងមហាភារតយុទ្ធ ចប់តែប៉ុណ្ណោះ ។

ព.ស. ២ ៤៩៨

គ.ស. ១ ៩៥៦

ប៊ូ-ប៉ូ

## ប្រាប់របៀបអានពាក្យ

### ក

| | ត្រូវអានថា |
|---|---|
| កក្ខឡកម្ម | *កាក់ ខាក់ ឡាក់ កាំ* (អំពីអាក្រក់) |
| កតិកា | *កាក់ តិ កា* (ពាក្យប្ដេជ្ញា) |
| កនភវន | *កាក់ នាក់ ភាក់ វាន់* (ឈ្មោះព្រៃ) |
| កន្តារ | *កន់ តា* (ផ្លូវឆ្ងាយដាច់ស្រយាល) |
| កន្យា | *កន់ យ៉ា* (ស្ត្រី) |
| កម៌ | *កាក់ រាក់ មាក់* (អំពើ, ការងារ) |
| កម្មវិបាក | *កាំ មាក់ វិ បាក* (ផលរបស់កម្ម) |
| កមលសន្តាន | *កាក់ ម៉ល់ សន់ ដាន* (ចិត្ត) |
| កមលហឫទ័យ | *កាក់ ម៉ល់ ហាក់ ឫ ទៃ* (ចិត្ត) |
| កល្បាវសាន | *កាល់ ប៉ា វាក់ សាន* (ទីបំផុតកល្ប) |
| កលោបាយ | *កាក់ លោ បាយ* (កល និងឧបាយ) |
| ក្សត្រិយាទ័ព | *ក្សាត់ យា ទាប់* (ព្រះនាមស្ដេច) |
| កាណ៌ | *កា* (ត្រចៀកស្ដេច) |
| កាមសរ | *កា ម៉ាក់ ស* (សរ គឺសេចក្ដីស្រឡាញ់) |
| កាយទ្វារ | *កា យាគ ទ្វារ* (ទ្វារគឺកាយ) |



| | |
|---|---|
| ការុណ្យចិត្ត | *កា រុន ណ្យាក់ ចិត្ត* (ចិត្តអាណិត) |
| កាលកិរិយា | *កា លាក់ កិ រិ យ៉ា* (សេចក្ដីស្លាប់) |
| កិត្តិប្រវត្តិ | *កិត តិ ប្រ វាត់* (ប្រវត្តិនៃកេរ្តិ៍) |
| កិត្តិមស័ក្តិ | *កិត តិ ម៉ាក់ សាក់* (ស័ក្តិមានកេរ្តិ៍) |
| ក្រឹស្ណៈ | *ក្រឹ ស្នាក់* (ព្រះនាមស្ដេច) |
| កុរុរដ្ឋ | *កុ រុ រាត់* (ឈ្មោះដែន) |
| កុលស្ត្រី | *កុ លាក់ សាក់ ត្រី* (ស្ត្រីក្នុងត្រកូល) |
| កោរព | *កោ រប់* (ព្រះនាមស្ដេច) |
| កោសល | *កោ សល់* (ព្រះនាមស្ដេច) |
| កោសល្យ | *កោ សល់* (សេចក្ដីឈ្លាសវៃ) |

### ខ

| | |
|---|---|
| ខាណ្ឌវបថ | *ខាន ឌាក់ វាក់ បត់* (ឈ្មោះដែន) |

### គ

| | |
|---|---|
| គជ (គជ់) | *គជ់* (វត្ថុជុំដូចជាពក មាន សាច់រឹងដូចកែវ កើតមានក្នុងសរីរកាយ ក្នុងក្បាលនៃសត្វទាំងឡាយ ដូចជាគជខ្យង, គជត្រី, គជដំរី, គជក្រៀល ។) |
| គន្ធារព | *គន់ ធា រប់* (ព្រះនាមស្ដេច) |
| គិម្ហរដូវ | *គឹម ហ្មាក់ រដូវ* (រដូវក្ដៅ ខែប្រាំង) |

គូជរាត *គូ ជាក់ រ៉ាត*(ឈ្មោះក្រុង)

### ឃ

ឃដោត្កចៈ *ឃាក់ ដោ ត្កាក់ ចាក់*(ព្រះនាមស្តេច)

### ច

ចរិយវត្ត *ចាក់ រិ យាក់ វាត់*(វត្តដែលត្រូវប្រព្រឹត្ត)
ចេតិយ *ចេ ដី*(វត្ថុជាទីគោរព)
ចារបុរស *ចា រាក់ បុរស*(បុរសអ្នកស៊ើបការណ៍)
ចិន្តក្រវី *ចិន តាក់ ក្រវី*(អ្នកប្រាជ្ញខាងគំនិត)

### ឆ

ឆន្ទនិយម *ឆាន់ ទាក់ និ យំ*(កំណត់តាមការចូលចិត្ត)

### ជ

ជនក *ជាក់ នក់*(បិតា)
ជ័យទ្រថ *ជៃ ទ្រត*(ព្រះនាមស្តេច)
ជេដ្ឋកនិដ្ឋា *ជេត ថាក់ កាក់ និត ថា*(បងនិងប្អូន)
ជេដ្ឋភគិនី *ជេត ថាក់ ភាក់ គិ នី*(បងស្រី)
ជេដ្ឋបុគ្គល *ជេត ថាក់ បុក គល់*(បុគ្គលជាធំ)

### ត

តន្តុរបាល *តន់ តាក់ រាក់ បាល*(ព្រះនាមស្តេច)



តាលធ្វជ *តា លាក់ ធ្វាច់*(ទង់ជ័យរូបដើមត្នោត)
តិណទ្យាន *តិ ណៈ ទ្យាន*(សួនស្មៅ)
ត្រន្តិក *ត្រន់ ថិ កាក់*(ព្រះនាមស្តេច)

### ទ

ទសពិធរាជធម៌ *ទស់ សាក់ ពិត រាច ជាក់ ធ*(ធម៌សម្រាប់ព្រះមហាក្សត្រិយ៍ ១០ យ៉ាង)
ទស្សនវិទ្យា *ទស់ សាក់ នាក់ វិត ទ្យា*(វិទ្យាសម្រាប់មើល, សម្រាប់ឱ្យយល់ឃើញ)
ទារុណកម្ម *ទា រុ ណាក់ កាំ*(អំពើអាក្រក់)
ទាសភាព *ទា សាក់ ភាប*(ភាពជាខ្ញុំគេ)
ទ្វារកៈ *ទ្វា រាក់ កាក់*(ឈ្មោះប្រទេស)
ទ្វារបាល *ទ្វា រាក់ បាល*(អ្នករក្សាទ្វារ)
ទិនករ *ទិ នាក់ ក*(ព្រះអាទិត្យ)
ទិព្វរូប *ទិ ពាក់ រូប*(រូបជាទិព្វ)
ទិវង្គត *ទិ វង់ គត់*(ស្លាប់)
ទុរពលភាព *ទុ រាក់ ពល់ លាក់ ភាព*(ភាពជាអ្នកមានកម្លាំងខ្សោយ, តិច)
ទុរយោធន៍ *ទុ រាក់ យោត*(ព្រះនាមស្តេច)
ទុរមរស័ណ *ទុ រាក់ មាក់ រាក់ សាន់*(ព្រះនាមស្តេច)

ទុសយន្ត *ទុ សាក់ យន់*(ព្រះនាមស្តេច)

ទុបាសាសនៈ *ទុ បាក់ សា សាក់ នាក់*(ព្រះនាមស្តេច)

ទ្រុបទ *ទ្រុ បត់*(ព្រះនាមស្តេច)

ទេវសភាព *ទេ វាក់ សាក់ ភាប*(ភាពនៃទេវតា)

ទេវឱង្ការ *ទេ វាក់ អោង កា*(ពាក្យរបស់ទេវតា)

ទោណអាចារ្យ *ទោ ណាក់ អា ចា*(ឈ្មោះគ្រូបង្រៀន)

ទោសចិត្ត *ទោ សាក់ ចិត*(ចិត្តខឹង)

ទោសគ្គិ *ទោ សាក់ គិ*(ភ្លើងគឺទោសៈ)

ទ្រៅបទី *ព្រៅ ប៉ាក់ ទី*(ព្រះនាមព្រះរាជិនី)

## ធ

ធ្មតរាស្ត្រ *ទ្រឺ តាក់ រាស*(ព្រះនាមស្តេច)

ធ្មស្តទ្យុម័ន *ទ្រឺ ស្តាក់ ឌ្យុ ម៉ាន់*(ព្រះនាមស្តេច)

## ន

នកុល *នាក់ កុ លាក់ឬ កុល*(ព្រះនាមស្តេច)

នភតល *នាក់ ភាក់ ដុល*(ផ្ទៃអាកាស)

នលាដ *នាក់ ឡាត*(ថាស)

នារទ *នា រាក់ ទាក់ឬ នា រត*(ឈ្មោះអ្នកប្រាជ្ញ)

និទ្រា *និត ទ្រា*(ការដេកលក់)



និរន្តរ *និ រ៉ន់ ដ*(ឥតចន្លោះ)

និរន្តរកាល *និ រ៉ន់ តាក់ រាក់ កាល*(កាលឥតចន្លោះ)

និរយភូមិ *និ រាក់ យាក់ ភូម*(ទីនរក)

## ប

បក្សិនជាតិ *បាក់ សិន ជាត*(ជាតិសត្វមានស្លាប)

បាណ្ឌុ *បាន់ ឌុ*(ព្រះនាមស្តេច)

បពិត *ប រ៉ាក់ ពត់*(ភ្នំ)

បរសុរាម *ប៉ាក់ រាក់ សុ រាមៈ*(ឈ្មោះស្តេច  យក្ស)

បរម្បរគតិ *ប៉ាក់ រ៉ាំ ប៉ាក់ រាក់ គាក់ តិ*(គតិ ត ៗ   គ្នា)

បរម្បរសម្បត្តិ *ប៉ាក់ រ៉ាំ ប៉ាក់ រាក់ សំ បាត់*(សម្បត្តិ ត ៗ គ្នា)

បដិបក្ខ *ប៉ះ ដិ ប៉ុក*(សត្រូវ, គូវិវាទ)

បរមត្ថចរិយា *ប៉ាក់ រាក់ ម៉ាត់ ថាក់ ចាក់ រិ យា*
(សេចក្តីប្រព្រឹត្តយ៉ាងល្អិតសុខុម)

បរិវិតក្ក *ប៉ាក់ រិ វិ តុក*(សេចក្តីត្រិះរិះ)

បលាយនាការ *ប៉ាក់ ឡា យាក់ នា កា*(អាការរត់ចេញទៅ)

ប្រដិពល *ប្រ ដិ ពល់*(អង់អាចឈ្លាសវៃ)

បាណ្ឌពកុមារ *បាន ឌាប់ កុ មា៉*(ព្រះនាមស្តេច)

បាតាល *បា ដាល*(ស្ថានខាងក្រោយ)

បាទបរិចារិកា *បាត ប រិ ចា រិ កា*(ប្រពន្ធ)

បាទយុគល *បាត យុ គល់*(ជើងទាំងគូ)

បិតុលា *ប៉ិ តុ ឡា*(មា, ពួកខាងបិតា)

បិយោរស *ប៉ិ យោ រ័ស់*(កូនជាទីស្រឡាញ់)

ប្រិយមិត្រ *ប្រី យាក់ មិត*(មិត្រជាទីស្រឡាញ់)

ប្រីក្សិត *ប្រឹក សិត*(ព្រះនាមស្តេច)

បុព្វណ្ណជាតិ *បុប ពាន់ ណាក់ ជាត*(ស្រូវ, ពោត ......)

បៅរព *ប៉ៅ រប់*(ព្រះនាមស្តេច)

## ព

ពណ៌នា *ព័រ ណាក់ នា*(និយាយ, អធិប្បាយ)

ពនេចរ *ពន់ នេ ច*(ដើរក្នុងព្រៃ)

ពន្ធនាគារ *ពន់ ធាក់ នា គា*(ទីឃុំឃាំង, គុក)

ពលរាម *ពល់ លាក់ រាម*(ព្រះនាមស្តេច)

ពសុធា *ពាក់ សុ ធា*(ផែនដី)

ព្រហ្មចារិយ *ព្រំ មាក់ ចាក់ រិ យាក់*(ការប្រព្រឹត្តធម៌ដ៏ប្រសើរ)

ពាណិជ្ជកម្ម *ពា និច ជាក់ កាំ មាក់*(ការជំនួញ)

ពិតាន *ពិ ដាន*(ពិតានផ្ទះ)

ពិភព *ពិ ភប់*(ផ្ទៃលោក, ទីលំនៅ)



## ភ

ភរតៈ *ភាក់ រាក់ តាក់*(ព្រះនាមស្តេច)

ភាគិនេយ្យ *ភា គិ នៃ*(ក្មួយ)

ភីស្មៈ *ភី ស្មាក់*(ព្រះនាមស្តេច)

## ម

មកុដរាជកុមាររដ្ឋទាយាទ *ម្កុត រា ជាក់ កុ មា រ៉ាច់ ដាក់ ទា យាត*
(ព្រះមកុដរាជកុមារ ដែលត្រូវទទួល
សោយរាជ្យសម្បត្តិពីព្រះវររាជបិតា)

មច្ឆនគរ *មាច់ ឆាក់ ន គ*(ឈ្មោះទីក្រុង)

មតកភត្ត *មាក់ តាក់ កាក់ ភាត់*(ភត្តដែលគេធ្វើបញ្ជូនទៅឱ្យ
មនុស្សស្លាប់)

មទ្រៈ ឬមាទ្រៈ *ម៉ាត់ ទ្រាក់*(ឈ្មោះប្រទេស)

មធុរកថា *មាក់ ធុ រាក់ កាក់ ថា*(សំដីពីរោះ)

មនសិការ *មាក់ នាក់ សិ កា*(ធ្វើទុកក្នុងចិត្ត គឺយកចិត្ត
ទុកដាក់, តាំងចិត្ត, ផ្ចង់ចិត្ត)

មនោរថ *មាក់ នោ រ៉ុត*(សេចក្តីប្រាថ្នា)

មយូរា *មាក់ យូ រ៉ា*(សត្វក្ងោក)

មហាភារតយុទ្ធ *មាក់ ហា ភា រាក់ តាក់ យុត* (ឈ្មោះរឿងចម្បាំងយ៉ាងធំមួយ)

ម្រតក *ម្រើ ដក់* (ទ្រព្យកេរ, ទ្រព្យសម្បត្តិ)

ម្រត្យុរាជ *ម្រើ ត្យុ រាច* (ស្តេចគឺសេចក្តីស្លាប់)

មាល័យ *មា លៃ* (ភួងផ្កា)

មិគសញ្ញី *មិ គាក់ សាញ់ ញី* (សំគាល់ថាម្រឹគ)

មេរុបពិត *មេ រុ បរាក់ ពត់* (ភ្នំឈ្មោះមេរុ)

មោរាសិលាពណ៌ *មោ រ៉ា សិ ឡា ព័រ* (ថ្មមានពណ៌ដូចស្លាបក្ងោក)

**យ**

យមបាល *យាក់ មាក់ ប៉ាល* (អ្នករក្សាស្ថាននរក)

យាទវៈ *យា ទាក់ វាក់* (ឈ្មោះទីក្រុង)

យុទ្ធកម្ម *យុត ធាក់ កាំ* (ការចម្បាំង)

យុទ្ធមណ្ឌល *យុត ធាក់ មន់ ឌល់* (ទីចម្បាំង)

យុធិស្ធិរ *យុត ធិ សាក់ ថិ រាក់* (ព្រះនាមស្តេច)

យុយុត្សុ *យុ យុត ត្សុ* (ព្រះនាមស្តេច)

**រ**

រក្សសី *រាក់ សាក់ សី* (អារក្សទឹក, យក្សស្រី)

រត្តិកាល *រាក់ តិ កាល* (វេលាយប់)



រត្តិសម័យ *រាក់ តិ សាក់ មៃ* (វេលាយប់)

រណារង្គ *រាក់ ណាក់ រង់* (ទីចម្បាំង, ខ្មែរច្រើននិយាយថាឿណរង្គ, ឬអានថារ៉ន់-រង់ ក៏មាន)។

រម្យស្ថាន *រំ ម្យាក់ សាក់ ថាន* (ទីគួររីករាយ)

រហ័សកម្ម *រ ហាស សាក់ កាំ* (ការសម្ងាត់)

រាជកកុធភណ្ឌ *រាច ជាក់ កាក់ កុ ធាក់ ភាន់* (គ្រឿងសម្រាប់រាជ ៥ យ៉ាងគឺ មកុដ, ព្រះខ័ន, ស្វេតឆត្រ, សុព័ណ៌បាទុក, វាលវិជនី)

រាជភ័ដ *រាច ជាក់ ភាត់* (មនុស្សដែលស្តេចទ្រង់ចិញ្ចឹមរក្សា)

រាជសូយពិធី *រាច ស្វាក់ យាក់ ពិ ធី* (ពិធីបូជាស្តេច)

រានី *រ៉ា នី* (ព្រះរាជិនី, ស្តេចស្រី)

**ឧ**

វឌ្ឍភាព *វាត់ ធាក់ នាក់ ភាព* (សេចក្តីចម្រើន)

វចនវោហារ *វាក់ ចាក់ នាក់ វោ ហា* (ការប្រើពាក្យ)

វណ្ណិព្វកព្រាហ្មណ៍ *វាន់ និប ពាក់ កាក់ ព្រាម* (ព្រាហ្មណ៍អ្នកនិយាយរៀបរាប់)

វនប្រទេស *វាន់ នាក់ ប្រ ទេស* (ប្រទេសជាព្រៃ)

វន្ទនាការ *វាន់ ទាក់ នា កា* (ការថ្វាយបង្គំ)

វរកាយ — វក់ រក់ កាយ(កាយដ៏ប្រសើរ)

វរលញ្ឆករ — វក់ រក់ ឡាញ់ ឆាក់ ក(ត្រា, ព្រះសង្ហា)

វស្សានរដូវ — វៈ សាន រដូវ(រដូវភ្លៀង)

វាសុទេវិន — វ៉ា សុ ទេ វិន(ឈ្មោះទេវតា)

វារណាវ័ត — វ៉ា រក់ ណា វ៉ត់(ឈ្មោះព្រៃ)

វិចិត្តវិរ័យ — វិ ចិត វិ រ៉ៃ(ព្រះនាមស្តេច)

វិធវា — វិ ធាក់ វ៉ា ឬ វា(ស្ត្រីមេម៉ាយ)

វិនាសកម្ម — វិនា សាក់ កាំ(អំពើសាបសូន្យ)

វិប្បដិសារ — វិ ប៉ាក់ ដិ សា រក់(ស្តាយក្រោយ)

វិមលភក្ត្រ — វិ មាក់ លាក់ ភាក់(មុខឥតមន្ទិល)

វិវាហសមោទ្យ — វិវ៉ា ហាក់ សាក់ មោត(ការរីករាយក្នុងវិវាហមង្គល)

វិសុទ្ធកន្យា — វិ សុត ធាក់ កន់ យ៉ា(ស្ត្រីបរិសុទ្ធ)

## ស

សកុន្តលា — សាក់ កុន តាក់ ឡា(ព្រះនាមទេវី)

សណ្ហាវាចា — សន់ ណ្ហាក់ វា ចា(សំដីពីរោះ)

សតិវិបល្លាស — សាក់ តិ វិ ប៉ាក់ ឡាស់(វិលស្មារតី)

សន្តតិវង្ស — សន់ តាក់ តិ វង់(វង្សត ៗ គ្នា)

សន្តោស — សន់ ដោស(ប្រាជ្ញាតិច, គ្រាប្រណី)



សន្ធ្យា — សន់ ធាក់ យា(យប់, រាត្រី)

សម្មានស័ក្តិ — សាំ ម៉ា នាក់ សាក់(ស័ក្តិគួររាប់អាន)

សមោសរ — សាក់ ម៉ោ ស(ប្រជុំព្រម)

សល្យរាជា — សល់ ល្យាក់ រា ជា(ព្រះនាមស្តេច)

សវនីយ៍ — សៈ វ៉ៈ នី(សំដីរបស់ស្តេចស្រី ដែលប្រើក្លាយជាព្រះសៅវនីយ៍)

ស្មសាន — សំ សាន(ព្រៃស្មាត់, ព្រៃខ្មោច)

ស្វយម្ពរ — ស្វាក់ យ៉ាំ ព(ការរើសគូព្រេង)

ស្វយយជនកម្ម — ស្វាក់ យាក់ យាក់ ជាក់ នាក់ កាំ(ការធ្វើពិធីបូជាស្តេច)

សហទេព — សាក់ ហាក់ ទេប(ព្រះនាមស្តេច)

សាន្តនុ — សាន តាក់ នុ(ព្រះនាមស្តេច)

សាមន្តរាជ — សា ម៉ន់ តាក់ រាច(ស្តេចចំណុះ)

សារ័ណទូត — សា រ៉ាន់ ទូត(ព្រះនាមស្តេច)

សាសនកិច្ច — សា សាក់ ណាក់ កិច(កិច្ចក្នុងសាសនា)

សាហ័សកម្ម — សា ហាក់ សាក់ កាំ(កម្មឲ្យផលទាន់ហាន់, ឲ្យផលឆ្លាម ៗ)

សិខណ្ឌិន — សិ ខាន់ ឌិន(ព្រះនាមស្តេច)

សិន្ធព — សិន ធប់(ឈ្មោះសេះ)

| | |
|---|---|
| សិន្ធុ | *សិន ធុ* (ឈ្មោះប្រទេស) |
| សិល្បសាស្ត្រ | *សិល ប៉ាក់ សាស* (ចំណេះវិជ្ជា) |
| ស្រីត្រីស្ណះ | *ស្រី ត្រីះ ស្នាក់* (ព្រះនាមស្តេច) |
| សុនខ | *សុ ណក់* (ឆ្កែ) |
| សុរង | *សុ រ៉ង* (ក) |
| សុសរម័ន | *សុ សាក់ រាក់ ម៉ាន់* (ព្រះនាមស្តេច) |
| សុវានសត្វ | *សុ វ៉ាន សាត់* (ឆ្កែ) |
| ស្នមយាចក | *ស្នម យា ចក់* (អ្នកសូមទាន) |
| ស្លែងសោត់ | *ស្លែង សោត* (ស្លែងដល់ត្រចៀក) |

**ហ**

| | |
|---|---|
| ហីនទោស | *ហី នាក់ ទោស* (ទោសថោកទាប) |

**អ**

| | |
|---|---|
| អគារស្ថាន | *អាក់ គា រាក់ ស្ថាន* (ទីផ្ទះ) |
| អគ្និ | *អាក់ គ្និ* (ភ្លើង) |
| អង្គរក្ស | *អង់ គាក់ រាក់* (អ្នករក្សាអង្គ) |
| អច្ចយោទោស | *អាច់ ចាក់ យោ ទោស* (សុំទោស) |
| អចិវាសនខន្តិ | *អាក់ ចិ វា សាក់ ណាក់ ខាន់ តិ* (សេចក្តីអត់សង្កត់ចិត្តយ៉ាងក្រៃលែង) |



| | |
|---|---|
| អនាថបាណ្ឌព | *អាក់ ណា ថាក់ បាន ឌាប់* (បាណ្ឌពដែលឥតទីពឹង, កំព្រា) |
| អនុជ | *អាក់ ណុច* (ប្អូន) |
| អនេកនិករជន | *អាក់ ណែក និ ក ជន់* (ប្រជុំជនច្រើន) |
| អន្តេបុរដ្ឋាន | *អន់ តេ ប៉ុ រ៉ាត់ ឋាន* (ខាងក្នុងបុរី) |
| អបលោក | *អាក់ ប៉ាក់ ឡោក* (ចែកឲ្យ) |
| អបរណ្ណជាតិ | *អាក់ ប៉ាក់ រ៉ន់ ណាក់ ជាត* (វត្ថុដែលត្រូវបរិភោគក្រោយ, ម្ហូប) |
| អប្បយស | *អាប់ ប៉ាក់ យស* (ឥតយស) |
| អបាយភូមិ | *អាក់ បា យាក់ ភូម* (ទីវិនាស, ទីមិនចម្រើន) |
| អភិមន្យុ | *អាក់ ភិ ម៉ន់ យុ* (ឈ្មោះស្តេច) |
| អភិលក្ខិតកាល | *អាក់ ភិ លាក់ ខិ តាក់ កាល* (កាលដែលកំណត់ទុក) |
| អភិសេកសមរស | *អាក់ ភិ សែក សំរស់* (រៀបផ្សំផ្គុំដោយអភិសេក) |
| អរជុន | *អាក់ រាក់ ជន* (ព្រះនាមស្តេចដែលខ្មែរយកមកឲ្យងារចៅហ្វាយខែត្រ ខែត្រត្បូងឃ្មុំជាឧកញ៉ាអរជូន) |
| អស្តង្គត | *អស់ ស្តង់ គត់* (ថ្ងៃលិចបាត់រស្មី) |
| អស្វត្ថាម័ន | *អាស់ ស្វាក់ ថា ម៉ន់* (ព្រះនាមស្តេច) |

អស្វមេធយញ្ញ *អាស់ ស្វាក់ មេ ធាក់ យ៉ាញ់*(ពិធីសម្លាប់សេះបូជា)

អស្វមេធ *អាក់ ស្វាក់ ម៉េធ*(ព្រះនាមស្តេច)

អស្សុជល *អាស់ សុ ជល់*(ទឹកភ្នែក)

អហំការ *អាក់ ហាំង កា*(ស្រេចលើអញ,

ឧ- ប្រកាន់ដាច់អហំការ ឬអហង្ការក៏បាន)

## អា

អាចិកំបាំង *អា កំ បាំង*(សេចក្តីសម្ងាត់)

អាចិណ្ណ *អា ចិន*(ជានិច្ច, ជាប់មិនដាច់)

អាណត្តិសញ្ញា *អា ណាត់ តិ សាញ់ ញ៉ា*(សញ្ញា បង្គាប់)

អាទរពល *អា ទាក់ រាក់ ពល់*(ពលអ្នកអើពើ)

អារណ្យវាសិន *អា រ៉ាន់ ណ្យាក់ វ៉ា ស៊ិន*(អ្នកនៅក្នុងព្រៃ)

អារញ្ញិកសត្វ *អា រ៉ាញ់ ញិ កាក់ សាត់*(សត្វនៅក្នុងព្រៃ)

## ឥ

ឥន្ទ្របថរដ្ឋ *ឥន ទ្រាក់ ប៉ាត់ រាត់*(ឈ្មោះដែន)

ឥរាវ័ត *ឥ រ៉ា វាត់*(ឈ្មោះស្តេច)

## ឧ

ឧរ *ឧ រាក់*(ទ្រូង)

ឧប្បត្តិ *ឧប ប៉ាត់*(កើតឡើង)



ឧប្បត្តិហេតុ *ឧប ប៉ាត់ តិ ហែត*(ហេតុកើតឡើង)

ឧបទ្ទវន្តរាយ *ឧ ប៉ាត់ ទាក់ វាន់ តាក់ រ៉ាយ*(ចង្រៃ និងអន្តរាយ

ឧបទ្រព)

## ឯ

ឯកមាតុទរ *ឯក មា តុ ទ*(ផ្ទៃម្តាយមួយ)

## ឱ

ឱរស *ឱ រ៉ស់* (កូនប្រុស, ព្រះរាជបុត្រ)

## ឬ

ឫសីវយាសៈ *ឫ សី វាក់ យា សាក់* (ឈ្មោះតាបស)